**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ..៣៥៦...ស.ខ.ល.

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតរចនាសម្ព័ន្ធចំណុះអនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

-បានឃើញអនុក្រឹត្យលេខ ៣៧អនក្រ.បក ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

-បានឃើញអនុក្រឹត្យលេខ ៥៧អនក្រ.បក ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

-បានឃើញអនុក្រឹត្យលេខ ៨៥អនក្រ.បក ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩

-បានឃើញសេចក្តីសម្រេចលេខ ៦៧សសរ ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០២១ ស្តីពីតែងតាំងសមាសភាព គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

-បានឃើញសេចក្តីសម្រេចលេខ ៦៩សសរ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០២១ ស្តីពីសមាសភាព និងការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩

-បានឃើញសេចក្តីសម្រេចលេខ ៨០សសរ ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០២១ ស្តីពីតែងតាំងសមាសភាព នៃអនុគណៈកម្មការដឹកនាំអនុវត្តច្បាប់ ចំណុះឲ្យគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩

-យោងតាមសំណើរបស់អនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតរចនាសម្ព័ន្ធចំណុះឲ្យអនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់ ដូចខាងក្រោម ៖

- លេខាធិការដ្ឋាន
- ក្រុមការងារសម្របសម្រួលនីតិវិធី
- ក្រុមការងារប្រតិបត្តិការ

លេខាធិការដ្ឋាន និងក្រុមការងារនីមួយៗ ដឹកនាំដោយប្រធាន ០១រូប អនុប្រធាន និងសមាជិកមួយចំនួនតាមការចាំបាច់។

សមាសភាពជាក់ស្តែង នៃលេខាធិការដ្ឋាន និងក្រុមការងារនីមួយៗ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធាន **គ.អ.ក.** ។

**ប្រការ២.-**

លេខាធិការដ្ឋាន ជាសេនាធិការឱ្យអនុគណៈកម្មការដឹកនាំអនុវត្តច្បាប់ ដែលមានភារកិច្ចដូចខាងក្រោម ៖

- សម្របសម្រួលការអនុវត្តវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការច្បាប់ ដើម្បីបង្ការទប់ស្កាត់ និងគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ទទួលបន្ទុកលើការងាររដ្ឋបាល ពិធីការ និងការរៀបចំកិច្ចប្រជុំនានារបស់អនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់
- រៀបចំផែនការសកម្មភាព និងដាក់ចេញផែនការណែនាំ ឬសេចក្តីណែនាំផ្សេងទៀត ដើម្បីពង្រឹងការអនុវត្តវិធានការនានាពាក់ព័ន្ធដល់ការទប់ស្កាត់ និងប្រយុទ្ធការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ពិសេសមេរោគបំប្លែងថ្មី របស់អនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់
- លើកវិធានការចាំបាច់នានា ដើម្បីពង្រឹងប្រសិទ្ធភាពការងាររបស់អនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់ និងលើកសំណើដាក់ចេញវិធានការថ្មីៗ ដើម្បីឆ្លើយតបទៅនឹងការវិវត្ត នៃសភាពការណ៍ជាក់ស្តែង
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃអំពីវឌ្ឍនៈភាព នៃការអនុវត្តវិធានការនានា របស់រចនាសម្ព័ន្ធចំណុះឲ្យអនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់ និងធ្វើរបាយការណ៍ជាប្រចាំជូនអនុប្រធានគណៈប្រតិបត្តិ នៃ**គ.អ.ក** ដែលទទួលបន្ទុកអនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់ ក

- សម្របសម្រួលការងារជាមួយក្រុមការងារចំណុះអនុគណៈកម្មការ ដើម្បីសម្រេចការងាររួមរបស់អនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់
- ធ្វើប្រតិកម្មបកស្រាយបំភ្លឺទាន់ពេលវេលា ជូនសាធារណៈជនសំដៅវាយបក និងបន្សាបឥទ្ធិពលនូវព័ត៌មានមិនពិត បំពុលបរិយាកាសសង្គម ប៉ះពាល់ដល់ការអនុវត្តវិធានច្បាប់ និងវិធានការនានាពាក់ព័ន្ធដល់ការទប់ស្កាត់ និងប្រយុទ្ធនឹងជំងឺកូវីដ-១៩
- រៀបចំបូកសរុបរបាយការណ៍ និងលើកទិសដៅការងាររបស់អនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ជូនរបស់អនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់។

**ប្រការ៣.-**

ក្រុមការងារសម្របសម្រួលនីតិវិធី ជាសេនាធិការឱ្យអនុគណៈកម្មការដឹកនាំអនុវត្តច្បាប់ ដែលមានភារកិច្ចដូចខាងក្រោម ៖

- សេនាធិការជូនអនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់ ដើម្បីសម្របសម្រួលនីតិវិធីដល់ក្រុមការងារប្រតិបត្តិការ ក្នុងការអនុវត្តវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការច្បាប់
- ធ្វើការណែនាំដល់ក្រុមប្រតិបត្តិការអំពីនីតិវិធីនានា ពិន័យអន្តការណ៍ និងការកសាងសំណុំរឿងបញ្ជូនទៅតុលាការ
- សហការសម្របសម្រួលជាមួយ របនាសម្ព័ន្ធចំណុះឲ្យអនុកម្មការដឹកនាំអនុវត្តច្បាប់ ដើម្បីសម្រេចភារកិច្ចរបស់ខ្លួន
- សម្របសម្រួលការងារជាមួយយន្តការពាក់ព័ន្ធដើម្បីគ្រប់គ្រងប្រាក់ពិន័យអន្តរការណ៍ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព
- រាយការណ៍ជាប្រចាំអំពីលទ្ធផលការងារជូនលេខាធិការដ្ឋាន នៃអនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់ ។

**ប្រការ៤.-**

ក្រុមការងារប្រតិបត្តិការ ជាសេនាធិការឱ្យអនុគណៈកម្មការដឹកនាំអនុវត្តច្បាប់ ដែលមានភារកិច្ចដូចខាងក្រោម ៖

- សេនាធិការជូនអនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់ ក្នុងការចាត់តាំងអនុវត្តជាក់ស្តែងលើការងារត្រួតពិនិត្យ ការងារបង្ការ ទប់ស្កាត់រាល់សកម្មភាពបំពាននឹងវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការផ្សេងទៀត ដែលអាជ្ញាធរ ឬស្ថាប័នមានសមត្ថកិច្ចបានដាក់ចេញក្នុងការបង្ការ ទប់ស្កាត់ និងគ្រប់គ្រង ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

- កសាងផែនការប្រតិបត្តិការ ដើម្បីបង្ការ ទប់ស្កាត់ រាល់សកម្មភាពបំពាន ឬរារាំងដល់ការអនុវត្តវិធានការសុខាភិបាល វិធានការរដ្ឋបាល វិធានការនានារបស់អាជ្ញាធរ ឬស្ថាប័នមានសមត្ថកិច្ច បានដាក់ចេញក្នុងការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩
- រៀបចំផែនការប្រើប្រាស់កម្លាំង មធ្យោបាយ ឧបករណ៍ សម្ភារៈ បម្រើឱ្យប្រតិបត្តិការ បង្ការទប់ស្កាត់រាល់សកម្មភាពល្មើសច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- សហការជាមួយ ក្រុមសម្របសម្រួលនីតិវិធីដើម្បីសម្រេចភារៈកិច្ចរបស់ខ្លួន
- ចាត់វិធានការពិន័យអន្តរការណ៍ និងវិធានការច្បាប់ចំពោះបុគ្គល និងនីតិបុគ្គលស្របតាមច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ព្រមទាំងអនុក្រឹត្យ និងបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធដល់ការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- រៀបចំកម្លាំងដើម្បីអន្តរាគមន៍ដោះស្រាយសភាពការណ៍ ក្នុងការអនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់ នៅពេលមានតម្រូវការចាំបាច់
- រាយការណ៍ជាប្រចាំអំពីលទ្ធផលប្រតិបត្តិការជូនលេខាធិការដ្ឋាន នៃអនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់
- អនុវត្តការកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់។

**ប្រការ៥.-**

គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី-ខេត្ត ត្រូវរៀបចំបង្កើតគណៈបញ្ជាការដឹកនាំការអនុវត្តច្បាប់នៅថ្នាក់រាជធានី-ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលជាសេនាធិការលើការងារអនុវត្តប្រតិបត្តិការរបស់អនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់ ។

គណៈបញ្ជាការដឹកនាំការអនុវត្តច្បាប់នៅថ្នាក់រាជធានី-ខេត្ត មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១.អភិបាលរងរាជធានី-ខេត្ត | សមាជិកអនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់ | ជាប្រធាន |
| ២.នាយករងរដ្ឋបាលរាជធានី-ខេត្ត | ចំនួន ១ រូប | ជាអនុប្រធាន |
| ៣.ស្នងការរងនគរបាលរាជធានី-ខេត្ត | សមាជិកអនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់ | ជាអនុប្រធាន |
| ៤.មេបញ្ជាការរងកងរាជអាវុធហត្ថរាជធានី-ខេត្ត | សមាជិកអនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់ | ជាអនុប្រធាន |
| ៥.អនុប្រធានមន្ទីរសុខាភិបាលរាជធានី-ខេត្ត | សមាជិកនៃអនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់ | ជាអនុប្រធាន |
| ៦.តំណាង១រូប នៃមន្ទីរ ឬអង្គភាពពាក់ព័ន្ធនានា | | ជាសមាជិក |
| ៧.អភិបាលក្រុង ស្រុក ខណ្ឌ | | ជាសមាជិក។ |

គណៈបញ្ជាការដឹកនាំការអនុវត្តច្បាប់នៅថ្នាក់ក្រុង ស្រុក ខណ្ឌ មានសមាសភាពដូចខាងក្រោម៖ ៷

១.អភិបាលក្រុង ស្រុក ខណ្ឌ ជាប្រធាន
២.អធិការនគរបាលក្រុង ស្រុក ខណ្ឌ ជាអនុប្រធាន
៣.មេបញ្ជាការមូលដ្ឋានកងរាជអាវុធហត្ថក្រុង ស្រុក ខណ្ឌ ជាអនុប្រធាន
៤.អនុប្រធានការិយាល័យសុខាភិបាល ក្រុង ស្រុក ខណ្ឌ ប្រតិបត្តិ ចំនួន ១រូប ជាសមាជិក
៥.តំណាង ១រូប នៃការិយាល័យ ឬអង្គភាពពាក់ព័ន្ធ ជាសមាជិក។

**ប្រការ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧.-**

គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ គណៈប្រតិបត្តិនៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ អនុគណៈកម្មការនានាចំណុះឲ្យគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ អនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់ និងអភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៣ រោច ខែ ទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០២១

**ម៉ម_ប៊ុនហេង**

**កន្លែងទទួល ៖**

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- -គណៈប្រចាំការ នៃគ.ប.ក
- -គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត
- -ដូចប្រការ៧
- -ឯកសារ កាលប្បវត្តិ